ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២០០០ សហវ-ទស

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មេសា ឆ្នាំ២០០៧

គោរពជូន

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាយកគ្រប់គ្រងគំរោងហិរញ្ញប្បទានសហប្រតិបត្តិការ ដោយធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក

កម្មវត្ថុ : ការកំណត់ប្រាក់ឧបត្ថម្ភ និងប្រាក់របបបេសកកម្ម ក្រោមក្របខ័ណ្ឌនៃគំរោងហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី និង ធនាគារពិភពលោក ។

យោង : - លិខិតលេខ ៧៥៨/៩៨ កអក គ.ជ.នា ចុះថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- អនុក្រឹត្យលេខ ១០ អនក្រ បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាលកម្ពុជា ។
- អនុក្រឹត្យលេខ ១០២ អនក្រ បក ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាលកម្ពុជា ។
- អនុក្រឹត្យលេខ ៩៨ អនក្រ បក ចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ។
- អនុក្រឹត្យលេខ ៣៨ អនក្រ បក ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ។
- លិខិតលេខ ៥៣៣៣ សហវ វស ចុះថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- លិខិតលេខ ៦៣៣១ សហវ វស ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- លិខិតលេខ ៧២៨៥ សហវ វស ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- អនុស្សរណៈនៃការយោគយល់រវាងរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ចុះថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ។
- ស្មារតីនៃកិច្ចប្រជុំអន្តរក្រសួងថ្ងៃទី ២៤ និងថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ និងថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ។
- អនុក្រឹត្យលេខ ១៤ អនក្រ បក ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ។

សេចក្តីដូចបានជំរាបជូនតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបឯកឧត្តម លោកជំទាវ លោក លោកស្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមកំណត់ប្រាក់ឧបត្ថម្ភ និងរបបបេសកកម្មក្នុងប្រទេស ក្រោមក្របខ័ណ្ឌនៃគំរោងហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី និង ធនាគារពិភពលោក ដូចមានខាងក្រោម:

## ក- ប្រាក់ឧបត្ថម្ភ :

១- គោលការណ៍ផ្តល់ប្រាក់ឧបត្ថម្ភដល់មន្ត្រីរាជការបំរើការងារក្រោមក្របខ័ណ្ឌ នៃគំរោងហិរញ្ញប្បទានសហប្រតិបត្តិការដោយធនាគារអភិវឌ្ឍន៍អាស៊ី និង ធនាគារពិភពលោក ត្រូវអនុវត្តស្មារតីលិខិតលេខ ៧៥៨/៩៨ កអក គ.ជ.នា ចុះថ្ងៃទី ២៥ ខែមិនា ឆ្នាំ ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទៅតាមតួនាទី និង កំរិតប្រាក់ឧបត្ថម្ភដូចខាងក្រោម :

| តួនាទីក្នុងគំរោង | ប្រាក់ឧបត្ថម្ភអតិបរិមា |
|---|---|
| ប្រធានគំរោង (Project Director/Coordinator/Officer) | ២៥០ ដុល្លារអាមេរិក ក្នុងមួយខែ |
| មន្ត្រីបច្ចេកទេស (Technical Staff) | ១៨០ ដុល្លារអាមេរិក ក្នុងមួយខែ |
| មន្ត្រីទ្រទ្រង់ ឬប្រតិបត្តិ (Supporting or Operational Staff) | ១០០ ដុល្លារអាមេរិក ក្នុងមួយខែ |

២- ភ្នាក់ងារប្រតិបត្តិគំរោងត្រូវពិភាក្សា និងឯកភាពជាមុន អំពីតួនាទី និងចំនួនមន្ត្រី ព្រមទាំងកំណត់កំរិតប្រាក់ឧបត្ថម្ភជាក់ស្តែងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣- ប្រាក់ឧបត្ថម្ភអាចផ្តល់ជូនមន្ត្រីរាជការបំពេញការងារអោយគំរោងដែលមានមុខតំណែងនៅក្នុងក្រសួង-ស្ថាប័ន ចាប់ពីថ្នាក់អគ្គនាយក ឬថ្នាក់ស្មើ ចុះក្រោម ។

៤- មន្ត្រីរាជការមួយរូបអាចទទួលប្រាក់ឧបត្ថម្ភតែពីគំរោងមួយប៉ុណ្ណោះ ។

៥- មន្ត្រីរាជការដែលមិនបំពេញការងារអោយគំរោងពេញម៉ោង នឹងទទួលប្រាក់ឧបត្ថម្ភតែពាក់កណ្តាល ឬទៅតាមចំនួនជាក់ស្តែងនៃពេលវេលាបំពេញការងារគំរោង ។

## ខ- ប្រាក់របបបេសកកម្ម :

១- គោលការណ៍ផ្តល់ប្រាក់របបបេសកកម្មក្នុងប្រទេសក្រោមក្របខ័ណ្ឌ នៃគំរោងហិរញ្ញប្បទានសហប្រតិបត្តិការដោយធនាគារអភិវឌ្ឍន៍អាស៊ី និង ធនាគារពិភពលោក មានដូចខាងក្រោម :

| ល.រ | បេសកកម្ម | ពីភ្នំពេញទៅខេត្ត | ពីខេត្តមកភ្នំពេញ | ក្នុងខេត្ត-ក្រុង និងឆ្លងខេត្ត | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ប្រាក់ហូបចុក | ១០ ដុល្លារអាមេរិក | ១០ ដុល្លារអាមេរិក | ៧ ដុល្លារអាមេរិក | បេសកកម្មរយៈពេលខ្លី មិនស្នាក់នៅពេលយប់ ផ្តល់ជូនតែប្រាក់ហូបចុកប៉ុណ្ណោះ ។ |
| ២ | ប្រាក់ស្នាក់នៅ | ១០ ដុល្លារអាមេរិក | ១៥ ដុល្លារអាមេរិក | ១០ ដុល្លារអាមេរិក | |
| ៣ | សោហ៊ុយធ្វើដំណើរ | ទូទាត់ផ្អែកលើបង្កាន់ដៃ ឬវិក័យប័ត្រជាក់ស្តែង (ក្នុងករណីការធ្វើដំណើរមិនមែនដោយមធ្យោបាយរបស់រដ្ឋ/គំរោង ) | | | |

២- គោលការណ៍ផ្តល់ប្រាក់របបបេសកកម្មខាងលើ ត្រូវអនុវត្តទូទៅសំរាប់មន្ត្រីរាជការគ្រប់ថ្នាក់ ដែលបំពេញការងារអោយគំរោង ។

៣- គោលការណ៍ផ្តល់ប្រាក់របបបេសកកម្មក្រៅប្រទេសក្រោមក្របខ័ណ្ឌ នៃគំរោងហិរញ្ញប្បទានសហប្រតិបត្តិការដោយធនាគារអភិវឌ្ឍន៍អាស៊ី និង ធនាគារពិភពលោក ត្រូវអនុវត្តស្មារតីអនុក្រឹត្យលេខ ១០ អនក្រ បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាលកម្ពុជា ។

គ- ប្រាក់របបឧបត្ថម្ភដោយឡែក :

១- គោលការណ៍ផ្តល់របបឧបត្ថម្ភសំរាប់ការប្រជុំ និងសិក្ខាសាលារបស់មន្ត្រីរាជការ ក្រោមក្របខ័ណ្ឌគំរោងទ្រទ្រង់វិស័យសុខាភិបាលដែលហិរញ្ញប្បទានដោយ ADB, WB, DFID និង UNFPA [Loan No. 1940-CAM (SF)] ត្រូវអនុវត្តស្មារតីលិខិតលេខ ៧២៨៥ សហវ វស ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

២- គោលការណ៍ផ្តល់ប្រាក់ឧបត្ថម្ភ និងសោហ៊ុយផ្សេងៗសំរាប់បេសកកម្ម ឆ្លងស្រុក-ខ័ណ្ឌ និង មិនឆ្លងស្រុក-ខ័ណ្ឌ ការរៀបចំវគ្គបំប៉ន និងការប្រជុំ ក្រោមក្របខ័ណ្ឌគំរោងទ្រទ្រង់វិស័យអប់រំកម្ពុជា ដែលហិរញ្ញប្បទានដោយ WB [IDA Credit No. 4055-KH និង Grant No. H161-KH] ត្រូវអនុវត្តស្មារតីលិខិតលេខ ៦៣៣១ សហវ វស ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឃ- ក្របខ័ណ្ឌនៃការអនុវត្តន៍ :

១- គោលការណ៍កំណត់ខាងលើនេះ ត្រូវអនុវត្តរហូតដល់ពេលមានគោលការណ៍ថ្មីត្រូវបានរៀបចំ ។

២- គោលការណ៍កំណត់ខាងលើនេះ អាចអនុវត្តសំរាប់គំរោងហិរញ្ញប្បទានសហប្រតិបត្តិការ ពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត ប្រសិនបើមានការព្រមព្រៀងពីដៃគូអភិវឌ្ឍន៍នោះ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ លោក លោកស្រីមេត្តាជ្រាប និងចាត់ចែងអនុវត្ត ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ តាមការគួរ ។

សូមឯកឧត្តម លោកជំទាវ លោក លោកស្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា
- ស្ថានតំណាងធនាគារពិភពលោកប្រចាំនៅកម្ពុជា
- ឯកសារ-កាលប្បវត្តិ